# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រុមហ៊ុន ព្រីមៀ ថេក ហ្គាម៉ិន (ខេមបូឌា) ឯ.ក

### កិច្ចព្រមព្រៀង
### រវាង

ក្រុមហ៊ុន ព្រីមៀ ថេក ហ្គាម៉ិន (ខេមបូឌា) ឯ.ក ជាមួយតំណាងកម្មករ និងសហជីពប្រចាំក្រុមហ៊ុន

ឆ្នាំពីរពាន់ម្ភៃពីរ ខែកញ្ញា ថ្ងៃទីមួយ វេលាម៉ោង១០និង០០នាទីព្រឹកនៅការិយាល័យរដ្ឋបាលរបស់ក្រុមហ៊ុន ព្រីមៀ ថេក ហ្គាម៉ិន (ខេមបូឌា) ឯ.ក មានកិច្ចប្រជុំពិភាក្សាមួយរវាងតំណាងក្រុមហ៊ុនជាមួយប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំសហជីពដើម្បីកម្មករ ប្រចាំរោងចក្រ។ ក្រោយពីបានប្រជុំពិភាក្សា ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោមៈ

១- ភាគីទាំងពីរយល់ព្រមព្យួរកិច្ចសន្យាការងាររយៈពេល៣០ថ្ងៃចំពោះកម្មករ និយោជិតចំនួន ៧៥នាក់ មាននៅផ្នែកតុកាតក្នុងរោងចក្រ ដោយគិតចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ដោយសារខ្វះវត្ថុធាតុដើម។

២-ភាគីកម្មករ និយោជិតយល់ព្រមទទួលប្រាក់ឧបត្ថម្ភចំនួន០១ដុល្លាអាមេរិចក្នុងមួយថ្ងៃពីក្រុមហ៊ុន។

៣-ក្រុមហ៊ុននិងបើកប្រាក់ឧបត្ថម្ភ០១ដុល្លាអាមេរិចក្នុងមួយថ្ងៃជូនកម្មករនិយោជិតនៅថ្ងៃទី១០ នៃខែបន្ទាប់

៤-បងប្អូនកម្មករ និយោជិតត្រូវត្រលប់ចូលធ្វើការវិញនៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២២ ក្នុងករណីបងប្អូនកម្មករ និយោជិតមិនបានចូលធ្វើការវិញតាមកាលកំណត់នោះទេក្រុមហ៊ុននិងអនុវត្តតាមច្បាប់ស្តីពីការងារ និងតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។

កិច្ចព្រមព្រៀងនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ០៦កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

តាកែវ,ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២

ស្នាមមេដៃតំណាងកម្មករ និងសហជីព

តំណាងក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ព្រីមៀ ថេក ហ្គាម៉ិន (ខេមបូឌា) ឯ.ក PREMIER TECH GARMENT (CAMBODIA) CO. LTD. KINGDOM OF CAMBODIA

Li Xunkai